ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
លេខ ០៦ ដន.ស.ក

ភ្នំពេញ, ថ្ងៃទី០៥ ខែ ឧសភាឆ្នាំ ២០០៦

# សារាចរណែនាំ

## ស្ដីពី

## គោលការណ៍ និង នីតិវិធីចុះបញ្ជីដីបំពេញបន្ថែម

ដោយពិនិត្យឃើញថា ក្រោយពីបានបញ្ចប់នីតិវិធីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធក្នុងតំបន់មួយចំនួនរួចមក នៅមានក្បាលដីខ្លះស្ថិតក្នុងតំបន់វិនិច្ឆ័យ ប៉ុន្តែម្ចាស់នៃក្បាលដីទាំងនោះមិនបានមកចូលរួមបំពេញបែបបទ ដើម្បីទទួលបានសិទ្ធិពេញលេញតាមកាលកំណត់ ។ ក្បាលដីទាំងនេះ មានស្ថានភាពខុសៗគ្នា មួយចំនួនត្រូវបានផ្តល់ប័ណ្ណសំគាល់សិទ្ធិរួចហើយតាមនីតិវិធីចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ឯមួយចំនួនទៀតត្រូវបានកាន់កាប់ត្រឹមត្រូវប៉ុន្តែមិនទាន់ត្រូវបានផ្តល់ប័ណ្ណសំគាល់សិទ្ធិនៅឡើយ ។ ទោះក្នុងករណីណា ក៏ការកាន់កាប់ស្របច្បាប់ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទាំងនេះ ត្រូវតែបានសំរួលឱ្យចុះចូលក្នុងសៀវភៅគោលបញ្ជីដីធ្លី ដើម្បីធានាសិទ្ធិពេញលេញតាមផ្លូវច្បាប់ ។

ក្នុងការសំរួលដោះស្រាយបញ្ហាខាងលើ ក្រសួងបានកំណត់នូវគោលការណ៍ និងនីតិវិធីនៃការចុះបញ្ជីដីបំពេញបន្ថែម ដូចតទៅ ៖

- ម្ចាស់អចលនវត្ថុដែលមិនបានចូលរួមបំពេញបែបបទ តាមកាលកំណត់ក្នុងពេលប្រកាសតំបន់វិនិច្ឆ័យ និងកិច្ចដំណើរការអនុវត្តនីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធដោយមានមូលហេតុសមស្រប **ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីដី** មកការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល(ការិ.ដនសក.) តាមរយៈមេឃុំ ចៅសង្កាត់ នៃឃុំ សង្កាត់ដែលជាទីតាំងនៃដីស្ថិតនៅ ។
- មេឃុំ ចៅសង្កាត់ត្រូវពិនិត្យលក្ខណៈសមស្រប ផ្តល់យោបល់ និងបញ្ជូនសំណុំរឿងមកការិ.ដនសក. ស្រុក ខណ្ឌ ។
- បើការិយាល័យជំនាញពិនិត្យឃើញសមស្រប រាយការណ៍ជូនអភិបាលស្រុក ខណ្ឌ ដើម្បីផ្តល់យោបល់ និង សហការចុះពិនិត្យទិដ្ឋភាពបច្ចេកទេស និងរដ្ឋបាល-គតិយុត្ត ហើយ**កំណត់ព្រំ វាស់វែង និងកសាងទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី** ដែលបានស្នើសុំ ។
- បើក្បាលដីស្នើចុះបញ្ជីស្ថិតនៅចន្លោះក្បាលដីដែលបានចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធរួចហើយ ព្រំនៃក្បាលដីនោះមិនចាំបាច់ធ្វើការកំណត់ជាថ្មីទៀតទេ ។ ចំពោះក្បាលដីដែលមិនទាន់បានកំណត់ព្រំជា

ផ្លូវការ ជាមួយក្បាលដីជាប់ព្រំគ្នាសោះ ឬបានកំណត់ព្រំខ្លះ ចាំបាច់ត្រូវធ្វើការកំណត់ព្រំដែលនៅសេសសល់ តាមនីតិវិធី ។ ត្រូវស្រង់យកចំណែកពាក់ព័ន្ធនឹងការចុះបញ្ជីបំពេញបន្ថែមនេះ ពីប្លង់សុរិយោដីដែលជាលទ្ធផលនៃការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធលើកមុន មកគូសបំពេញព្រំប្រទល់ដែលទើបកំណត់ក្រោយ ហើយដាក់លេខក្បាលដីតពីលេខលើកមុន ។

- ក្រោយពីរៀបចំសំណុំឯកសារគ្រប់គ្រាន់ ត្រូវ**បិទផ្សាយជាសាធារណៈ** នូវទិន្នន័យដែលប្រមូលបានក្នុងរយៈពេល ៣០ថ្ងៃ នៅសាលាសង្កាត់ និងនៅការិ.ដនសភ. ស្រុក ខណ្ឌ ។ រាល់ការជំទាស់ ឬតវ៉ា ត្រូវធ្វើនៅការិ.ដនសភ.ស្រុក ខណ្ឌ ។ ការកែតម្រូវអាចធ្វើបានតាមសមត្ថកិច្ច និងគោលការណ៍ដែលបានកំណត់ដោយអនុក្រឹត្យពាក់ព័ន្ធ ។
- ការិ.ដនសភ. ត្រូវធ្វើរបាយការណ៍បូកសរុប ផ្ដល់យោបល់ និងបញ្ជូនសំណុំរឿងមកអភិបាលស្រុក ខណ្ឌ ដើម្បីសុំយោបល់ ហើយបញ្ជូនបន្តមកមន្ទីរដនសស.ខេត្ត ក្រុង ពិនិត្យបន្ថែមលើលក្ខណៈបច្ចេកទេស រួចទើបបញ្ជូនទៅ**សាលាខេត្ត ក្រុង សុំយោបល់សំរេច** ។
- នៅពេលដែលអភិបាលខេត្ត ក្រុងយល់ព្រមហើយ សំណុំឯកសារនៃការវិនិច្ឆ័យត្រូវបញ្ជូនមកមន្ទីរដនសស.វិញ ដើម្បី**ធ្វើការចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី** និងក្នុង Digital file ហើយបោះពុម្ពប័ណ្ណ ចុះហត្ថលេខា រួចប្រគល់ជូនអ្នកស្នើសុំ ។ ករណីអភិបាលខេត្ត ក្រុងមិនយល់ព្រម ឬច្រានចោល ត្រូវបញ្ជាក់ឱ្យច្បាស់អំពី មូលហេតុដែលមិនយល់ព្រម ឬច្រានចោលនោះ ដើម្បីឆ្លើយតបទៅអ្នកស្នើសុំវិញ និងទុកជាឯកសារ ។

សារាចរណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**

**ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់**

**អ៊ឹម ឈុនលឹម**

កន្លែងទទួល

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត ក្រុង ដើម្បីជូនជ្រាបជាពត៌មាន
- គ្រប់អង្គភាពក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីមុខការ
- ឯកសារ-កាលប្បវត្តិ

ក្រដាសពុម្ពលេខ ១
ទីទុកឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យស្នើសុំចុះបញ្ជីដី បំពេញបន្ថែម

ខ្ញុំបាទ នាងខ្ញុំ ឈ្មោះ ........................................................ភេទ...............អាយុ................ឆ្នាំ សញ្ជាតិ...............................

ប្រពន្ធ-ប្តី ឈ្មោះ....................................................មានទីលំនៅ នៅភូមិ.......................................ឃុំ-សង្កាត់...............................

ស្រុក-ខណ្ឌ...............................................ខេត្ត-ក្រុង ........................................................ ។

### សូមគោរពជូន

**លោកអភិបាលស្រុក-ខណ្ឌ** ..................................................................................................................

__តាមរយៈ__ : - លោកមេឃុំ-ចៅសង្កាត់ ...................................................................................................................

- លោកប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក......................................................

__កម្មវត្ថុ__ : សំណើសុំចុះបញ្ជីដី

ដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ នាងខ្ញុំ បានកាន់កាប់ប្រើប្រាស់ដី...........................................................................

នៅភូមិ...........................ឃុំ-សង្កាត់...................................ស្រុក-ខណ្ឌ.................................ខេត្ត-ក្រុង...............................

ដែលមានទំហំប្រមាណ............................ចាប់ពីឆ្នាំ...................មកទល់បច្ចុប្បន្ន ។

ដីនេះមានព្រំប្រទល់ :

-ខាងជើងទល់នឹង ......................................................................................................................

-ខាងត្បូងទល់នឹង ......................................................................................................................

-ខាងកើតទល់នឹង ......................................................................................................................

-ខាងលិចទល់នឹង ......................................................................................................................

ដីនេះខ្ញុំបាទ នាងខ្ញុំបានមកពី....................................................................................................................................

ដីក្នុងតំបន់នេះត្រូវបានចុះបញ្ជីតាមនីតិវិធីមានលក្ខណៈជាប្រព័ន្ធរួចហើយ ប៉ុន្តែក្បាលដីរបស់ខ្ញុំបាទ នាងខ្ញុំមិនទាន់បានចុះបញ្ជីនៅ ឡើយដោយមូលហេតុ(១) .....................................................................................................................................

អាស្រ័យហេតុនេះសូមលោកអភិបាលស្រុក-ខណ្ឌ.......................................................................................................
មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឱ្យចុះបញ្ជីដីខ្ញុំបាទ នាងខ្ញុំដោយអនុគ្រោះ ។ ខ្ញុំបាទ នាងខ្ញុំសូមប្តេជ្ញាថា អនុវត្តរាល់កាតព្វកិច្ច និងបទបញ្ជាផ្សេងៗដែលរដ្ឋបានកំណត់ ។

ធ្វើនៅ ....................ថ្ងៃទី.........ខែ...............ឆ្នាំ ២០០.........

ស្នាមមេដៃ

លេខ .......................

បានឃើញ និងបញ្ជូនមកលោក
ប្រធានការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាល
ដើម្បីពិនិត្យ និងសម្រេចតាមការគួរ ។

......................ថ្ងៃទី..........ខែ...............ឆ្នាំ ២០០.....

មេឃុំ-ចៅសង្កាត់

ខេត្ត-ក្រុង :............................
ស្រុក-ខណ្ឌ :............................
លេខ :...................................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រដាសពុម្ពលេខ ២
ទីទុកឯកសារ

# សេចក្តីជូនដំណឹង

សូមប្រកាសជូនសាធារណជនឱ្យបានជ្រាបថា តាមពាក្យស្នើសុំចុះបញ្ជីដីធ្លីរបស់ :

១-ឈ្មោះ..........................................ដែលស្ថិតក្នុងភូមិ......................................ឃុំ/សង្កាត់......................................

មានព្រំប្រទល់ : ខាងជើងទល់នឹង......................................ខាងត្បូងទល់នឹង......................................

ខាងកើតទល់នឹង......................................ខាងលិចទល់នឹង...................................... ។

២-ឈ្មោះ..........................................ដែលស្ថិតក្នុងភូមិ......................................ឃុំ/សង្កាត់......................................

មានព្រំប្រទល់ : ខាងជើងទល់នឹង......................................ខាងត្បូងទល់នឹង......................................

ខាងកើតទល់នឹង......................................ខាងលិចទល់នឹង...................................... ។

៣-ឈ្មោះ..........................................ដែលស្ថិតក្នុងភូមិ......................................ឃុំ/សង្កាត់......................................

មានព្រំប្រទល់ : ខាងជើងទល់នឹង......................................ខាងត្បូងទល់នឹង......................................

ខាងកើតទល់នឹង......................................ខាងលិចទល់នឹង...................................... ។

៤-ឈ្មោះ..........................................ដែលស្ថិតក្នុងភូមិ......................................ឃុំ/សង្កាត់......................................

មានព្រំប្រទល់ : ខាងជើងទល់នឹង......................................ខាងត្បូងទល់នឹង......................................

ខាងកើតទល់នឹង......................................ខាងលិចទល់នឹង...................................... ។

ដែលនឹងត្រូវចុះអង្កេតវាស់វែងនៅថ្ងៃ...................................... ។

អាស្រ័យហេតុនេះ សូមអញ្ជើញសាមីអ្នកស្នើសុំចុះបញ្ជីដី អ្នកមានដីជាប់ព្រំ និងជនដែលមានការពាក់ព័ន្ធនឹងក្បាលដីស្នើសុំចុះបញ្ជីចូលមកបង្ហាញខ្លួននៅទីតាំងដីខាងលើនៅថ្ងៃ..............................វេលាម៉ោង....................ដើម្បីបំពេញបែបបទតាមនីតិវិធីនៃការចុះបញ្ជីដីធ្លីជាបរមាន ។ ក្នុងករណីអវត្តមាន អាជ្ញាធរស្រុក/ខ័ណ្ឌ មិនទទួលខុសត្រូវចំពោះបញ្ហាផ្សេងៗ ដែលអាចកើតឡើងជាយថាហេតុឡើយ ។

ធ្វើនៅ.......................ថ្ងៃទី........ខែ.............ឆ្នាំ២០០...

អភិបាលស្រុក/ខ័ណ្ឌ

<u>សេចក្តីជូនដំណឹងនេះបិទនៅ:</u>

-សាលាស្រុក/ខ័ណ្ឌ ...................................... ១ច្បាប់
-សាលាឃុំ/សង្កាត់...................................... ១ច្បាប់
-ទីស្នាក់ការភូមិ (ទីកន្លែងដី)...................................... ១ច្បាប់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

ក្រដាសពុម្ពលេខ (
ទីទុកឯកសារ

# ទម្រង់បែបបទ

# នៃការប្រមូលទិន្នន័យក្បាលដី

ក-អត្តសញ្ញាណនៃក្បាលដី :

១-លេខសំគាល់ក្បាលដី :

| ខេត្ត | ស្រុក | ឃុំ | ភូមិ | លេខក្បាលដី |
|---|---|---|---|---|
| | | | | |

សន្ទឹកផែនទី:..........................

២ -ទីតាំងដី :

ខេត្ត/ក្រុង.......................... ស្រុក/ខណ្ឌ..........................ឃុំ/សង្កាត់..........................ភូមិ..........................

ក្រុម..........................ផ្លូវលេខ..........................ឡូតិ៍..........................ឈ្មោះដី..........................

៣-មធ្យោបាយធ្វើអត្តសញ្ញាណកម្មក្បាលដី : អរតូហ្វូតូ ☐ ឧបករណ៍វាស់វែង .......................... ផ្សេងៗ: ..........................

៤-ប្រភពនៃការកាន់កាប់ដី : កាលបរិច្ឆេទនៃការកាន់កាប់លើកដំបូង:..........................ឯកសារយោង:..........................

ទិញ ☐ ដូរ ☐ សន្តតិកម្ម ☐ អំណោយ ☐ សម្បទានដីសង្គមកិច្ច ☐ អំណោយពីរដ្ឋ ☐ សេចក្តីសំរេចតុលាការ ☐

កាលបរិច្ឆេទ:..........................ឯកសារយោង:..........................

៥-ព័ត៌មានលំអិតនៃក្បាលដី :

៥.១ រូបភាពប្រើប្រាស់ដី : សាងសង់ ☐ :..........................

កសិកម្ម ☐ :..........................

ផ្សេងៗ:..........................

៥.២ លក្ខណៈនៃការប្រើប្រាស់ : ឯកជន ☐ រដ្ឋ ☐

៦-ព័ត៌មានលំអិតអំពីសំណង់ :

៦.១ ប្រភេទសំណង់ : ភូមិគ្រឹះ ☐ ពាក់កណ្តាលភូមិគ្រឹះ ☐ រោងចក្រ ☐ រោងសិប្បកម្ម ☐ ផ្ទះឈើ ☐ ផ្ទះស្លឹក ☐

ផ្ទះល្វែង ☐ ឃ្លាំង ☐ ផ្សេងៗ:..........................

៦.២ ឆ្នាំសាងសង់ :.............. ៦.៣ ចំនួនជាន់ :........... ៦.៤ ឈ្មោះនៃអគារ ( បើសិនជាមាន ) : ..........................

ខ-ព្រំប្រទល់ក្បាលដី : ស្នាមមេដៃ និងលេខក្បាលដីអ្នកជាប់ព្រំ

គំនូសបន្ទាញទីតាំងក្បាលដី

រូបសណ្ឋាននិងប្រវែងជ្រុងក្បាលដី

ក្រឡាផ្ទៃ :............ហត............អា...............សអា

## ខ. អត្តសញ្ញាណនៃម្ចាស់អចលនវត្ថុ :

១-រូបវន្តបុគ្គល :

| | ប្តី | ប្រពន្ធ |
|---|---|---|
| អត្តសញ្ញាណប័ណ្ណ/សំបុត្រកំណើត | | |
| ឈ្មោះ | | |
| ថ្ងៃ ខែ ឆ្នាំ កំណើត | | |
| ទីកន្លែងកំណើត | | |
| សញ្ជាតិ | | |
| ឈ្មោះឪពុក | | |
| ឈ្មោះម្តាយ | | |
| ទីលំនៅបច្ចុប្បន្ន | | |

២-នីតិបុគ្គល : សាធារណៈ ☐ ឯកជន ☐ សញ្ជាតិ ..............................

លក្ខន្តិកៈ ☐ ឈ្មោះអង្គភាព/នាមករណ៍:..............................................................................................

កាលបរិច្ឆេទនៃការចុះបញ្ជី :..............................លេខចុះបញ្ជី :..............................ឯកសារយោង :..............................

អាស័យដ្ឋាន (ទីស្នាក់ការ) :..............................................................................................

៣-អ្នកតំណាង ឬអ្នកគ្រប់គ្រង:

ឈ្មោះ :..............................ភេទ.............. ឆ្នាំកំណើត..............សញ្ជាតិ..............លេខអត្តសញ្ញាណប័ណ្ណ :..............................

មុខងារ ..............................................................ឯកសារយោង..............................................................

## គ.សិទ្ធិលើអចលនវត្ថុ :

១-ប្រភេទទ្រព្យ

រួមប្ដីប្រពន្ធ(BC) ☐ ផ្ទាល់ខាងប្រពន្ធ (PF) ☐ ផ្ទាល់ខាងប្ដី (PM) ☐ លក់ ☐ រដ្ឋ ☐ នីតិបុគ្គលសាធារណៈផ្សេងពីរដ្ឋ ☐

ទ្រព្យវត្ត ☐ សហគមន៍ជនជាតិដើមភាគតិច ☐ ក្រុមហ៊ុន ☐ ទ្រព្យសមាគម ☐ ព្រះរាជទ្រព្យ ☐

កម្មសិទ្ធិអវិភាគ ☐ សហកម្មសិទ្ធិ ☐ ផ្សេងៗ:..............................................................................................

២-ស្ថានភាពផ្លូវច្បាប់: មានបណ្ណ ☐ គ្មានបណ្ណ ☐ លេខបណ្ណ :..............................................................

ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ☐ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ☐ ប័ណ្ណកាន់កាប់បណ្ដោះអាសន្ន (POT) ☐

វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ☐ ផ្សេងៗ:..............................................................................................

៣-បន្ទុកលើអចលនវត្ថុ :

ផលុបភោគ ☐ សិទ្ធិប្រើប្រាស់និងអាស្រ័យនៅ ☐ សេវភាព ☐ ហ៊ីប៉ូតែក ☐ ការបញ្ចាំ ☐ ការដាក់ធានា ☐

ការជួលរយៈពេលវែង ☐ សម្បទានដីសង្គមកិច្ច ☐ សម្បទានសាជីវកម្មកសិ-ឧស្សាហកម្ម ☐ សម្បទានផ្សេងទៀតលើដីដែលជាទ្រព្យរដ្ឋ ☐

ឯកសារយោង:..............................................................................................

៤-ព្រំប្រទល់ដីទំនាស់: គ្មាន ☐ មាន ☐ : សំរុះសំរួលបាន ☐ សំរុះសំរួលមិនបាន ☐ មិនបានសំរុះសំរួល ☐ (ភ្ជាប់កំណត់ហេតុសំរុះសំរួលជាវិភាគ)

៥-ស្នាមមេដៃស្ដាំម្ចាស់ទ្រព្យនិងសាក្សី :

| ប្ដី | ប្រពន្ធ | តំណាង | សាក្សីទី១ | សាក្សីទី២ |
|---|---|---|---|---|
| ឈ្មោះ.............................. | ឈ្មោះ.............................. | ឈ្មោះ.............................. | ឈ្មោះ.............................. | ឈ្មោះ.............................. |

៦-ឈ្មោះអ្នកផ្ដល់ពត៌មាន :..............................................ស្នាមមេដៃ

អង្កេត វាស់វែង និងវិនិច្ឆ័យដោយ ..............................................................

.............. នៅថ្ងៃទី ..............ខែ .............. ឆ្នាំ..............

បានត្រួតពិនិត្យត្រឹមត្រូវ

ប្រធានការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និង ភូមិបាល

.............. នៅថ្ងៃទី ..............ខែ .............. ឆ្នាំ..............